10	បៀវត្ស និង ប្រាក់បំណាច់	2.165,0
11	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	2.450,0
31	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	10,0
32	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	5,0
	សរុប ៣១	**4.630,0**
	៩៩.ចំណាយមិនទាន់បែងចែក	
12	ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការអង្គការសាធារណៈរដ្ឋបាល	90.000,0
20	ការប្រាក់នៃការខ្ចី រយៈពេលវែង មធ្យម និង ខ្លី	45.000,0
40	ចំណាយផ្សេងៗ	85.400,0
41	ចំណាយមិនបានគ្រោងទុក	20.000,0
50	វិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស	325.000,0
51	វិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់	700.000,0
53	ការរំលស់បំណុល	95.000,0
	សរុប ៩៩	**1.360.400,0**
	សរុបចំណាយចរន្ត	**1.891.000,0**
	ក្នុងនោះ : រដ្ឋបាលកណ្តាល	**1.438.325,0**
	មន្ទីរជំនាញ ខេត្ត ក្រុង	**452.675,0**
	សរុបចំណាយជាមូលធន	**1.120.000,0**
	សរុបចំណាយថវិកាជាតិរបស់រដ្ឋ	**3.011.000,0**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរអគារ ចលនទ្រព្យ អចលនទ្រព្យ ឯកសារពាក់ព័ន្ធ និង មន្ត្រីរាជការ ក្របខ័ណ្ឌ នៃសាលាជាតិកសិកម្មកំពង់ចាម និង សាលាជាតិកសិកម្ម ព្រែកលៀប ពីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ អោយមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការផ្ទេរអាគារ ចលនទ្រព្យ អចលនទ្រព្យ និងឯកសារពាក់ព័ន្ធរបស់ក្រសួងអប់រំ យុវជន និង កីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងសាធារណការ និង ដឹកជញ្ជូន អតីតក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា អោយមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់ នៃការងារ

សម្រេច

មាត្រា ១.-

ត្រូវបានផ្ទេរការអាគារ ចលនទ្រព្យ អចលនទ្រព្យ ឯកសារពាក់ព័ន្ធ និងមន្ត្រីរាជការក្របខ័ណ្ឌ នៃសាលាជាតិកសិកម្មកំពង់ចាម និង សាលាជាតិកសិកម្មព្រែកលៀប ពីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ មកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។-

មាត្រា ២.–

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣.–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន អភិបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៧៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា ១. -

ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ចំនួន ០៣ គ្រឿង ជូនអ្នកឯកទេសបារាំង ចំនួន ០៣ រូប ដែលបានផ្តល់ថវិកាចំនួន ៤០០.០០០ USD ជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ស្ថិតនៅក្នុងមន្ទីរពេទ្យព្រះកុសុមៈ ដូចមានរាយនាមខាងក្រោម ÷

ក.មេដាយសហមេត្រី ថ្នាក់ **ធិបឌិន្ទ** :

- លោកវេជ្ជបណ្ឌិត **ព្យែរ រេហ្ស៊ីស ម៉ារតាំង** (**Pierre - Régis Martin**) ប្រធានគំរោងរបស់ក្រុមគ្រូពេទ្យពិភពលោកបារាំង

ខ.មេដាយសហមេត្រី ថ្នាក់ **អស្សឫទ្ធិ** :

១-លោកវេជ្ជបណ្ឌិត **ហ្សង់ ហ្វីលីព ឌូសេ** (**Jean – Philippe DOUSSET**) អ្នកសំរបសំរួលវេជ្ជសាស្ត្រ របស់គំរោង VIH/SIDA

២-លោក **ហ្សូអែល ឌុយរ៉ង់** (**Jöel DURAND**) អ្នកបច្ចេកទេសមន្ទីរពិសោធន៍

មាត្រា ២. -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦០១ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយសុវត្ថារា
ចេញ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សម្រេច

មាត្រា ១.

ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **អស្សឫទ្ធិ** ជូនមន្ត្រី នៃ ចំការកៅស៊ូជុប ចំនួន ០២រូប ដែលមានស្នាដៃល្អក្នុងការបំរើការងារផលិតកម្មកៅស៊ូ ដូចមានរាយនាមខាងក្រោម :-

១-លោក **សុក សាម** នាយករដ្ឋបាល និង ជាសមាជិកក្រុមប្រឹក្សាភិបាល ចំការកៅស៊ូជុប

២-លោក **ឡាច សាលី** ជំនួយការប្រធានអគ្គនាយក ចំការកៅស៊ូជុប

មាត្រា ២.

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

B.33

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦០៤ អនក្រ.ត៩

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សម្រេច

មាត្រា ១. ~

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រី នៃ ចំការកៅស៊ូជុប ចំនួន ០៣រូប ដែលមានស្នាដៃល្អក្នុងការបំរើការងារ ផលិតកម្មកៅស៊ូ ដូចមានរាយនាមខាងក្រោម :-

១-លោក **មាស មានិត**	នាយកបច្ចេកទេស ចំការកៅស៊ូជុប
២-លោក **ឈុន គង់មាន**	នាយកហិរញ្ញវត្ថុ ចំការកៅស៊ូជុប
៣-លោក **ហ៊ឹម អួន**	នាយកចំការកៅស៊ូ ទីរ៉ង នៃ ចំការកៅស៊ូជុប

មាត្រា ២. ~

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

B..32

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦០៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

១- លោកវរសេនីយ៍ទោ តាន ទ្រី អត្តលេខ ០៩៤៩
២- លោកវរសេនីយ៍ទោ សៀង ស៊ុខ អត្តលេខ ០៦០៦
៣- លោកវរសេនីយ៍ទោ មាស ច័ន្ទសុផល អត្តលេខ ០១០៤២
៤- លោកវរសេនីយ៍ទោ អន បូរ៉ាមី អត្តលេខ ០១០៤៤
៥- លោកវរសេនីយ៍ទោ លីម សោម អត្តលេខ ០១២២១
៦- លោកវរសេនីយ៍ទោ ម៉ឿន ចាន់ដារ អត្តលេខ ០១៤១៦
៧- លោកវរសេនីយ៍ទោ យ៉ុម សារិន អត្តលេខ ០១៥២៤
៨- លោកវរសេនីយ៍ទោ គីម សាខន អត្តលេខ ១២៣៤៤

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៥ សសរ

សេចក្ដីសម្រេច
ស្ដីពីការតែងតាំងទីប្រឹក្សាសម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានា នូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

សម្រេច

ប្រការ ១.-

តែងតាំង លោក **ឃ្លួន គុគឈួន** ជាទីប្រឹក្សាសម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

ប្រការ ២.-

លោក **ឃ្លួន គុគឈួន** ត្រូវអនុវត្តនូវសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាលកម្ពុជា
Royal Government of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

N°: 68. D.C.M

DECISION

The appointment of an Advisor to the Prime Minister of the Kingdom of Cambodia

***

The Royal Government

-Having seen the constitution of the Kingdom of Cambodia

-Having seen the Reachkrom N° NS/RKM / 0704 / 001 dated July 13,2004 which promulgated the additional Constitution law to ensure the normal proceeding of the State Institutions.

-Having seen the Royal Decree N° NS/RKT / 0704 / 124 dated July 15, 2004 on the appointment of the Royal Government of the Kingdom of Cambodia

-Having seen the Reachkrom N° 02 /NS/94 dated July 20 ,1994 which promulgated the law on the organization and functioning of the Council of Ministers

- Pursuant to the needs of the Royal Government of Cambodia

Hereby Decides :

Article 1 : To appoint Mr. **GOON KOK LOON** as an Advisor to Samdech Hun Sen, Prime Minister of the Kingdom of Cambodia, responsible for Sihanoukville Port Development.

Article 2 : Mr. **GOON KOK LOON** , The Ministry of Public Works and Transport and the Sihanoukville Port Authority have to implement this decision from the date of its signature.

Phnom Penh, November 05, 2004

Prime Minister

HUN SEN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៧ សសរ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មការគ្រប់គ្រង ការងារសិក្សាគំរោងប្លង់ រួមទីតាំង នៃស្ថាបត្យកម្ម និងប្លង់សាងសង់វិមានយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-យោងតាមការចាំបាច់

សម្រេច

ប្រការ១.-

បង្កើតគណៈកម្មការគ្រប់គ្រងការងារសិក្សាគំរោងប្លង់រួមទីតាំងនៃស្ថាបត្យកម្ម និងប្លង់សាងសង់វិមានយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្តម **យឹម ណុលឡា**   ទីប្រឹក្សារាជរដ្ឋាភិបាល   ប្រធាន

២-ឯកឧត្តម **ឆី យ៉ាច**	អនុប្រធាន ក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌	អនុប្រធាន
៣-ឯកឧត្តមបណ្ឌិតរដ្ឋ **តិច សំណាង**	អគ្គលេខាធិការនៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា	សមាជិក
៤-ឯកឧត្តម **អ៊ឹក សុមេត្ត**	អគ្គនាយករង អាជ្ញាធរអប្សរា	សមាជិក
៥-ឯកឧត្តម **ម៉ម សុផារ៉ា**	អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់	សមាជិក
៦-លោក **ហ៊ុយ ណារ៉ា**	អគ្គនាយករងនៃអគ្គនាយកដ្ឋានសំណង់	សមាជិក
៧-លោក **ឆាយ ឫទ្ធិសែន**	អនុប្រធានមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ	សមាជិក

ប្រការ២.-

គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

-គ្រប់គ្រង និងដឹកនាំការងារសិក្សាគំរោងប្លង់រួមទីតាំងនៃស្ថាបត្យកម្ម និងគំរោងប្លង់បច្ចេកទេសសាងសង់វិមានយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ។

-តាមដាន ត្រួតពិនិត្យ និងជំរុញដំណើរការការងារខាងលើតាមដំណាក់កាល ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលជាពតិមាន និង ពិនិត្យសំរេច ។

-ធ្វើទំនាក់ទំនងជាមួយបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូលពតិមានចាំបាច់សំរាប់បំរើអោយការងារសិក្សាខាងលើទទួលបានសំរេចលទ្ធផលល្អប្រសើរ ។

-ធ្វើការគណនាតំលៃនៃការចំណាយ សំរាប់ការងារសាងសង់នេះទាំងមូល ដើម្បីលើកជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

ប្រការ ៣.-

គណៈកម្មការមានសិទ្ធិបង្កើតក្រុមសិក្សាគំរោងប្លង់ស្ថាបត្យកម្ម និង ប្លង់បច្ចេកទេសសាងសង់ តាមតម្រូវការ ដើម្បីធានាអោយបានសំរេចភារកិច្ចខាងលើ ទាន់ពេលវេលាតាមការកំណត់ ។

ប្រការ ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១[illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិកាដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិកាដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ៤

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១ សរណន

សារាចរណែនាំ
ស្ដីពី
ការបញ្ជូនគណប្រតិភូទៅបំពេញបេសកកម្មនៅបរទេស

កន្លងមករាជរដ្ឋាភិបាលបានសង្កេតឃើញថា គ្រប់ក្រសួង ស្ថាប័ន បានដំណើរការចូលរួមអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលយ៉ាងមមាញឹក ក្នុងនោះមានការបញ្ជូនគណប្រតិភូ ទៅបំពេញទស្សនកិច្ច ចូលរួមសន្និសីទ កិច្ចប្រជុំអន្តរជាតិនានានៅបរទេសជាបន្តបន្ទាប់ ។ ប៉ុន្តែមានក្រសួង ស្ថាប័នមួយចំនួន បានបញ្ជូនគណប្រតិភូទៅបំពេញបេសកកម្ម នៅបរទេស ពុំបានជូនពត៌មានឱ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតំណាងស្ថានទូតកម្ពុជា ប្រចាំនៅបរទេសចូលរួមនៅក្នុងសកម្មភាពជាមួយគណប្រតិភូ ដើម្បីសំរបសំរួល និងតាមដានរាល់កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងជាមួយបណ្ដាប្រទេសទាំងនោះនៅឡើយ ។

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិឱ្យកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលសូមណែនាំ ដល់គ្រប់ក្រសួង ស្ថាប័នថា ចាប់ពីពេលនេះតទៅ សូមឱ្យគ្រប់ក្រសួង ស្ថាប័នរដ្ឋ ដែលបញ្ជូនគណប្រតិភូទៅបំពេញបេសកកម្ម នៅបរទេស ត្រូវផ្ដល់ពត៌មានជូនទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិឱ្យបានមុន ដើម្បីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានលទ្ធភាពជូនដំណឹង ឬចាត់ឱ្យស្ថានទូតកម្ពុជា ជួយសំរួលបេសកកម្មរបស់គណប្រតិភូផង និងចូលរួមក្នុងសកម្មភាពនានារបស់គណប្រតិភូផង ។ ក្រោយពេលបំពេញបេសកកម្ម គណប្រតិភូគ្រប់ក្រសួង ស្ថាប័នរដ្ឋ ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល និងចម្លងជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានលទ្ធភាពបន្តតាមដានការងារទាំងនោះជាបន្តទៀត ។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចចាត់ឯកអគ្គរាជទូត ឬតំណាងស្ថានទូតឱ្យចូលរួមទៅតាមករណីគណប្រតិភូនិមួយៗ។

ចំពោះរាល់ទស្សនកិច្ចនៅបរទេស របស់ថ្នាក់ដឹកនាំនៃគ្រប់ក្រសួង ស្ថាប័ន ចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើងទៅ ត្រូវសុំការអនុញ្ញាតពីរាជរដ្ឋាភិបាលជាមុនសិន ។

ទទួលបានសារាចរណែនាំនេះ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមខ្លឹមសារខាងលើនេះឱ្យបានសំរេចលទ្ធផលជាវិជ្ជមាន ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង និងស្ថាប័ន
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច និងឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ:...០៣០...សហវ.អគ.

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០០៤

សេចក្តីជូនដំណឹង

ស្តីពី
ការពន្យារពេលអនុវត្តប្រមូលពន្ធលើ
មធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៤

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានកិត្តិយសសូមជំរាបលោក-លោកស្រីដែលជាម្ចាស់យានយន្តគ្រប់ប្រភេទមេត្តាជ្រាបថា : ចាប់តាំងពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាស លេខ ២២៧ សហវ.ប្រក.ពដ ចុះថ្ងៃទី០៤ ខែ សីហា ឆ្នាំ២០០៤ និងសេចក្តីជូនដំណឹងលេខ ០១៤ សហវ.ពដ ចុះថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០០៤ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៤ លោក-លោកស្រី ជាម្ចាស់យានយន្តគ្រប់ប្រភេទមួយចំនួន ប្រកបដោយស្មារតីភ្ញាក់រលឹកយកចិត្តទុកដាក់គោរពកាតព្វកិច្ចបង់ពន្ធយ៉ាងច្រើនកុះករជាបន្តបន្ទាប់ ។

ក្នុងគោលបំណងដើម្បីឱ្យការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៤ ទទួលបានលទ្ធផលល្អប្រសើរថែមទៀតនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំរេចពន្យារពេលការប្រមូលពន្ធនេះរហូតដល់ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៤ ។

ចាប់ពីថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៤តទៅ អង្គភាពពន្ធដារនឹង**ធ្វើការត្រួតពិនិត្យដាក់ពិន័យចំនួនមួយដង ស្មើប្រាក់ពន្ធ បន្ថែមលើប្រាក់ពន្ធដែលត្រូវបង់** ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជឿជាក់ថាលោក-លោកស្រី ដែលជាម្ចាស់យានយន្ត ពិតជានឹងយកចិត្តទុកដាក់បំពេញកាតព្វកិច្ចសារពើពន្ធបានល្អជាមិនខាន ។

ចម្លងជូន:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
"ដើម្បីជ្រាបជាពត៌មាន"
- គ្រប់សាខាពន្ធដារគ្រប់ខេត្ត-ក្រុង
- ឯកសារ.កាលប្បវត្តិ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No.១៣៣១ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤

ប្រកាស
ស្តីពី
ការឈប់ផ្តល់នូវទិកំយប័ត្រពាណិជ្ជកម្មចំពោះមុខទំនិញមួយចំនួន

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិ ទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្របក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្ត ទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង
- យោងតាមសភាពការណ៍ចាំបាច់ដើមឆ្នាំ ២០០៥ ក្រោយកម្ពុជាចូលជាសមាជិក អង្គការពាណិជ្ជកម្ម ពិភពលោក ។

សំរេច

ប្រការ ១ : វិក័យប័ត្រពាណិជ្ជកម្ម (Commercial Invoice) នឹងត្រូវបញ្ឈប់ផ្តល់ជូនជាស្ថាពរដល់ អ្នកនាំចេញទំនិញសំលៀកបំពាក់ និង វាយនភ័ណ្ឌ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ មកជាមួយនេះ ។

ប្រការ ២ : វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម C/O Form N នឹងត្រូវបានចេញជូនអ្នកនាំចេញនូវប្រភេទ ទំនិញខាងលើក្នុងគោលបំណងគ្រប់គ្រងបរិមាណនិងតំលៃនាំចេញពីកម្ពុជា និងគ្រប់គ្រងសន្និធិវត្ថុ ធាតុដើមរបស់រោងចក្រ ។

ប្រការ ៣ : នីតិវិធីក្នុងការផ្តល់វិញ្ញាបនប័ត្រដូចប្រការ២ និង កាតព្វកិច្ចក្នុងការបង់សោហ៊ុយរដ្ឋបាល គឺនៅរក្សាជាធរមានដូចមានចែងក្នុងប្រកាសលេខ ១៥៩ ពណ. បអពប្រក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤ និង ១៨៦ ពណ. បអពប្រក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៤ ។

ប្រការ ៤ : នាយិកាខុទ្ទកាល័យ អគ្គាធិការ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ត្រូវអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

ចម្លងជូន :
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- ដូចប្រការ ៤
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

CAMBODIA

Visas are no longer required for the following integrated items. Items marked in bold (Category 331) are items that have newly become quota-free.

Category	Items
222	All Items
223	All Items
229	All Items
239	All Items except HTS 6209.20.5040
330	All Items
331	**Hts Items 6116.10.1720, 6116.10.4810, 6116.10.5510, 6116.10.7510, 2116.92.6410, 6116.92.6420, 6116.92.6430, 6116.92.6440, 116.92.7450, 6116.92.7460, 6116.92.7470, 6116.92.8800, 6116.92.9400, 6116.99.9510**
349	All items
350	All items
353	All items
354	All items
359	HTS items 6115.19.8010, 6117.10.6010, 6117.20.9010, 6203.22.1000, 6204.22.1000, 6212.90.0010, 6214.90.0010, 6406.99.1550, 6505.90.1525, 6505.90.1540, 6505.90.2060 and 6505.90.2545
369	HTS items 4202.12.4000, 4202.12.8020, 4202.12.8060, 4202.22.4020, 4202.22.4500, 4202.22.8030, 4202.32.4000, 4202.32.9530, 4202.92.0805, 4202.92.3016, 4202.92.6091, 5601.10.1000, 5601.21.0090, 5701.90.1020, 5701.90.2020, 5702.10.9020, 5702.39.2010, 5702.49.1020, 5702.49.1080, 5702.59.1000, 5702.99.1010, 5702.99.1090, 5705.00.2020, 5805.00.3000, 5807.10.0510, 5807.90.0510, 6301.30.0010, 6301.30.0020, 6302.51.1000, 6302.51.2000, 6302.51.3000, 6302.51.4000, 6302.60.0010, 6302.60.0030, 6302.91.0005, 6302.91.0025, 6302.91.0045, 6302.91.0050, 6302.91.0060, 6303.11.0000, 6303.91.0010, 6303.91.0020, 6304.91.0020, 6304.92.0000, 6305.20.0000, 6306.11.0000, 6307.10.1020, 6307.10.1090, 6307.90.3010, 6307.90.4010, 6307.90.5010, 6307.90.8910, 6307.90.8945, 6307.90.9905, 6307.90.9982, 6406.10.7700, 9404.90.1000, 9404.90.8040, 9404.90.9505
431	All items
432	All items
439	All items
459	HTS items 6115.19.8020, 6117.10.1000, 6117.10.2010, 6117.20.9020, 6212.90.0020, 6214.20.0000, 6405.20.6030, 6405.20.6060, 6405.20.6090, 6406.99.1505, and 6406.99.1560
464	All items
465	All items
469	HTS items 5601.29.0020, 5603.00.1010, 6304.19.3040, 6304.91.0050, 6304.99.1500, 6304.99.6010, 6308.00.0010, 6406.10.8020 and 6406.10.9020
600	All items
606	All items
607	All items
621	All items
622	All items

Category	Items
630	All items
631	HTS items 6116.10.1730, 6116.10.4820, 6116.10.5520, 6116.10.7520, 6116.93.8800, 6116.93.9400, 6116.99.4800, 6116.99.5400, 6116.99.9530
632	All items
649	All items
650	All items
653	All items
654	All items
659	HTS items 6115.11.0010, 6115.12.2000, 6117.10.2030, 6117.20.9030, 6212.90.0030, 6214.30.0000, 6214.40.0000, 6406.99.1510 and 6406.99.1540
665	All items
666	HTS items 5805.00.4010, 6301.10.0000, 6301.40.0010, 6301.40.0020, 6301.90.0010, 6302.53.0010, 6302.53.0020, 6302.53.0030, 6302.93.1000, 6302.93.2000, 6303.12.0000, 6303.19.0010, 6303.92.1000, 6303.92.2010, 6303.92.2020, 6303.99.0010, 6304.11.2000, 6304.19.1500, 6304.19.2000, 6304.91.0040, 6304.93.0000, 6304.99.6020, 6307.90.9984, 9404.90.8522 and 9404.90.9522
669	All items
670	All items
800	All items
810	All items
831	All items
832	All items
833	All items
834	All items
835	All items
836	All items
840	All items
842	All items
843	All items
844	All items
847	All items
850	All items
851	All items
858	All items
859	All items
870	All items
871	All items
899	All items

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: ១៤៧៣ អយក ប្រ.ក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន ទូរ៉ី

ស្ថិតនៅក្នុងឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤_១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៤ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « ហ៊ុន សែន ទូរ៉ី » ស្ថិតនៅក្នុងឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ចាប់ពីឆ្នាំសិក្សា ២០០៤_២០០៥ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ថ្ងៃទី១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤

បណ្ឌិត កុល ផេង

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តកំពង់ចាម " ដើម្បីជាពត៌មាន"
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\Lower-New.doc

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខៈ ១៤៧៦ អយក ប្រក

ប្រកាស

ស្តីពីការពង្រីកអនុវិទ្យាល័យ « អង្គសុរភី »ទៅជាវិទ្យាល័យ « អង្គសុរភី »
ស្ថិតនៅក្នុងឃុំកន្ទោខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤_១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់ការិយាល័យអប់រំ យុវជន និងកីឡាស្រុកកំពង់ត្រាច លេខ ២៤១អយក.សកតចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៤ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពត
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ « អង្គសុរភី » បច្ចុប្បន្ន ទៅជាវិទ្យាល័យ « អង្គសុរភី » ស្ថិតនៅក្នុងឃុំកន្ទោខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ចាប់ពីឆ្នាំសិក្សា ២០០៤_២០០៥ តទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃ វិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត និងនាយកវិទ្យាល័យសាមីមានភារកិច្ច រៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ខែ វិច្ឆិកា ឆ្នាំ ២០០៤

បណ្ឌិត កុល ផេង

<u>កន្លែងទទួល</u>
_ទីស្តីការគណៈរដ្ឋមន្ត្រី
_រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
_ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីជ្រាបជាពត៌មាន"
_សាលាខេត្តកំពត "ដើម្បីជាពត៌មាន"
_ដូចប្រការ ៥
_កាលប្បវត្តិ_ឯកសារ ន.មចទ

C:\New school\Increase.doc

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខៈ ១៤៧៧ អយក ១.៨

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ ជ្រោះប៊ូស្រា
ស្ថិតនៅក្នុងឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤_១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អវ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំប៊ូស្រា ស្រុកពេជ្រាដា ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តមណ្ឌលគិរី
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « ជ្រោះប៊ូស្រា » ស្ថិតនៅក្នុងឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ចាប់ពីឆ្នាំសិក្សា ២០០៤_២០០៥ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

បណ្ឌិត កុល ផេង

<u>កន្លែងទទួល</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តមណ្ឌលគិរី " ដើម្បីជាពត៌មាន"
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\Lower-New.doc

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខៈ ១៤៧៥ អយក.ប្រក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ អូររាំង
ស្ថិតនៅក្នុងឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤_១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី.២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនបឋមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំសែនមនោរម្យ ស្រុកអូររាំង ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៤ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តមណ្ឌលគិរី
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « អូររាំង » ស្ថិតនៅក្នុងឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ចាប់ពីឆ្នាំសិក្សា ២០០៤_២០០៥ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ថ្ងៃទី ...១ ខែ វិច្ឆិកា ឆ្នាំ ២០០៤

បណ្ឌិត គុល ប៉េង

__កន្លែងទទួល__ :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តមណ្ឌលគិរី " ដើម្បីជាពត៌មាន"
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\Lower-New.doc

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ: ១៤៧១ អយក.ប្រក

ប្រកាស

ស្តីពីការប្តូរឈ្មោះវិទ្យាល័យ « សាយ ឈុំ កោះសូទិន » ទៅជាវិទ្យាល័យ « កោះសូទិន »
ស្ថិតនៅក្នុងឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤_១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាគឺរត១_គឺរត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំកោះសូទិន ស្រុកកោះសូទិន ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៤ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះវិទ្យាល័យ « សាយ ឈុំ កោះសូទិន » បច្ចុប្បន្ន ទៅជាវិទ្យាល័យ « កោះសូទិន » ស្ថិតនៅក្នុងឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ចាប់ពីឆ្នាំសិក្សា ២០០៤_២០០៥ តទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម និងនាយកវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ខែ [illegible] ឆ្នាំ ២០០៤

បណ្ឌិត កុល ពេជ

<u>កន្លែងទទួល :</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " <u>ដើម្បីជ្រាបជាពត៌មាន</u>"
- សាលាខេត្តកំពង់ចាម " <u>ដើម្បីជាពត៌មាន</u>
- ដូចប្រការ ៣
- កាលប្បវត្តិ_ឯកសារ ឆា.មចទ

NewSchool-Takeo-OL